# ការព្យាបាលការញៀនគ្រឿងស្រវឹង និង គ្រឿងញៀន

Alcohol and Drug Treatment: How It Works, And How It Can Help You

## តើការព្យាបាលដំណើរការយ៉ាងដូចម្តេច និង តើការព្យាបាលអាចជួយអ្នកបានដោយរបៀបណា

- តាមរយៈប្រព័ន្ធតុលាការព្រហ្មទណ្ឌ
- តាមរយៈជីវិតដែលនៅសល់របស់អ្នក





U.S. DEPARTMENT OF HEALTH AND HUMAN SERVICES
Substance Abuse and Mental Health Services Administration
Center for Substance Abuse Treatment
www.samhsa.gov

This brochure informs people involved in the criminal justice system and their families about substance abuse treatment resources in prison and in the community. It describes what can be gained through substance abuse treatment while a person is incarcerated, on probation, or on parole. It encourages people to seek help for substance use disorders and stresses the importance of family support when seeking this assistance. To view the English version, please visit http://www.kap.samhsa.gov/products/brochures/consumer/index.htm




# ទំនាក់ទំនងជាមួយនឹងប្រព័ន្ធតុលាការព្រហ្មទណ្ឌ គឺជាឱកាសមួយសម្រាប់អ្នក ដើម្បីធ្វើការផ្លាស់ប្តូរជាវិជ្ជមាន ។

ហេតុអ្វីត្រូវទទួលការព្យាបាល ? ការប្រើប្រាស់ គ្រឿងញៀន ឬ គ្រឿងស្រវឹង អាចនាំអោយមានការចាប់ខ្លួនអ្នក ឬ ការចាប់ខ្លួនសារជាថ្មី ។ ដោយសារការប្រើគ្រឿងញៀន ឬ គ្រឿងស្រវឹង គឺជាឥរិយាបទឧក្រិដ្ឋមួយ ដែលមិនអាចអត់អោនទោសអោយបាន ដូច្នេះហើយការចាប់ខ្លួនរបស់អ្នកផ្តល់ ឱកាសមួយអោយអ្នកដើម្បីផ្តាច់ការញៀនថ្នាំ ឬ គ្រឿងស្រវឹង ។ ទោះបីជាអ្នកត្រូវបានដោះលែង ឬ ជាប់ឃុំឃាំងក៏ដោយ អ្នកគួរពិចារណាពីការព្យាបាលបញ្ហាការញៀនថ្នាំ ឬ គ្រឿងស្រវឹងរបស់អ្នក ។

អ្នកនៅតែត្រូវឆ្លងកាត់ដំណើរការរបស់តុលាការព្រហ្មទណ្ឌ ។ សូមសួរថាតើមានតុលាការគ្រឿងញៀនឬទេ ។

- អ្នកប្រហែលជាអាចជ្រើសរើសការព្យាបាលការញៀនថ្នាំ ជំនួសអោយការជាប់ពន្ធនាគារ ឬ មន្ទីរឃុំឃាំងវិញ ។
- អ្នកអាចទទួលការកាត់ទោសកាន់តែស្រាល ឬ ការចោទប្រកាន់របស់អ្នកអាចត្រូវបានច្រានចោល ប្រសិនបើអ្នកព្រមទទួលធ្វើការព្យាបាល ។ តែទោះជាយ៉ាងណាក៏ដោយ ប្រសិនបើអ្នកមិនធ្វើតាមកម្មវិធីនេះទេ ការចោទប្រកាន់របស់អ្នកគឺអាចនៅដូចដើម ហើយអ្នកអាចទទួលបានការកាត់ទោសកាន់តែធ្ងន់ ។

ការព្យាបាលគឺត្រូវការពេលវេលា ។ វាគឺជាការងារដ៏លំបាកមួយ ប៉ុន្តែវាផ្តល់អោយអ្នកនូវឱកាសមួយដែលប្រសើរ ជាជាងការទទួលការកាត់ទោស ។

តើការព្យាបាលការញៀនថ្នាំ និង គ្រឿងស្រវឹងគឺជាអ្វី ? ការព្យាបាលមានន័យថា :

- ការទៅចូលរួមក្នុងការពិគ្រោះយោបល់ និង ការជួបប្រជុំជាក្រុមស្តីពីគ្រឿងញៀន
- ការជៀសអោយឆ្ងាយពីមនុស្ស  ទីកន្លែង និង ស្ថានភាពដែលអាចនាំអោយអ្នកមានបញ្ហា
- ការសហការជាមួយនឹងអ្នកពិគ្រោះយោបល់របស់អ្នក ដើម្បីបង្ហាញថាអ្នកពិតជាកំពុងព្យាយាមធ្វើការផ្លាស់ប្តូរជីវិតរបស់អ្នក
- ការសិក្សាពីអ្វីៗដូចជា ការគ្រប់គ្រងកំហឹង និង ជំនាញការងារ ដូច្នេះហើយអ្នកអាចមានជម្រើសបន្ថែមទៀតនៅក្នុងជីវិតរបស់អ្នក ។

តើខ្ញុំចាប់ផ្តើមនៅកន្លែងណា ?

- ត្រូវទទួលស្គាល់ថាអ្នកមានជម្ងឺ និង នឿយហត់ចំពោះការមានបញ្ហា ។
- សុំគ្រួសាររបស់អ្នកអោយជូនអ្នកទៅធ្វើការព្យាបាល និង ស្នាក់នៅកន្លែងព្យាបាល ។
- ប្រសិនបើអ្នកជាប់នៅក្នុងពន្ធនាគារ   អ្នកគួរសុំតុលាការ ឬ មន្ត្រីព្យួរទោស អោយជួយដោះស្រាយបញ្ហាញៀនថ្នាំ ឬ គ្រឿងស្រវឹងរបស់អ្នក ។
- ប្រសិនបើអ្នកត្រូវបានដោះលែងអោយនៅក្រៅការឃុំឃាំង ដោយការបង់ប្រាក់ធានា នោះអ្នកមានប្រភពផ្សេងៗទៀត ។ សូមសួរមេធាវីរបស់អ្នក ឬ មន្ត្រីតុលាការអំពីកម្មវិធីនៅក្នុងតំបន់នោះ ឬ សូមមើលខាងក្រោយខ្នងនៃខិតប័ណ្ណនេះ ។

## អ្នកអាចមានជម្រើស និង ឱកាសច្រើនជាងអ្នកគិតទៅទៀត ។



នេះគឺជាមធ្យោបាយបន្ថែមមួយចំនួនទៀត ដើម្បីស្វែងរកជំនួយ :

- ទូរស័ព្ទមកកាន់លេខទូរស័ព្ទ 1-800-662-4357 ហើយការីម្នាក់នឹងប្រាប់អ្នក ថាតើមានកម្មវិធីព្យាបាលអ្វីខ្លះនៅក្បែរអ្នក ។ ឬ អ្នកអាចមើលពតិមានលើអ៊ីនធ័រណិត http://dasis3.samhsa.gov/ ។
- ក្រុមអ្នកពិគ្រោះយោបល់មូលដ្ឋាន ផ្នែកគ្រឿងស្រវឹង និង ណាកូទិក ដែលមិនបញ្ចេញឈ្មោះ (Local Alcoholics Anonymous and Narcotics Anonymous groups) មានចុះនៅក្នុងសៀវភៅស (white pages) នៃសៀវភៅទូរស័ព្ទរបស់អ្នក ។
- កម្មវិធីព្យាបាលការញៀនថ្នាំ និង គ្រឿងស្រវឹងផ្សេងៗទៀត មានចុះនៅក្នុងសៀវភៅលឿង (yellow pages) ។ សូមមើលខាងក្រោម " ការសេពគ្រឿងញៀន (Drug Abuse)" ។
- កម្មវិធីព្យាបាលរបស់រដ្ឋមានចុះនៅក្នុងសៀវភៅខៀវ (blue pages) ស្ថិតនៅក្រោមនាយកដ្ឋានសុខភាពក្នុងតំបន់ ។

នៅពេលអ្នកធ្វើការព្យាបាល សូមពិភាក្សាជាមួយអ្នកពិគ្រោះយោបល់របស់អ្នក អំពីសិទ្ធិឯកជនរបស់អ្នក ។

វាជាជម្រើសរបស់អ្នកថាតើ
អ្នកនឹងដោះស្រាយស្ថានភាពបច្ចុប្បន្នរបស់អ្នកយ៉ាងដូចម្តេច ។
ការព្យាបាលការញៀនថ្នាំ គឺជាចាប់ផ្តើមនៃជីវិតដ៏ប្រសើរមួយ ។

This brochure was created to accompany the publication *Substance Abuse Treatment for Adults in the Criminal Justice System*, #44 in the Center for Substance Abuse Treatment's Treatment Improvement Protocol series.

**Acknowledgment**
This brochure was produced under the Knowledge Application Program (KAP), contract numbers 270-04-7049 and 270-09-0307, a Joint Venture of The CDM Group, Inc., and JBS International, Inc., for the Center for Substance Abuse Treatment (CSAT), Substance Abuse and Mental Health Services Administration (SAMHSA), U.S. Department of Health and Human Services (HHS). Christina Currier served as the CSAT Government Project Officer.

**Disclaimer**
The views, opinions, and content in this brochure are those of the authors and do not necessarily reflect the views, opinions, or policies of CSAT, SAMHSA, or HHS. No official support of or endorsement by CSAT, SAMHSA, or HHS for these opinions or for particular instruments, software, or resources is intended or should be inferred.

**Public Domain Notice**
All material appearing in this brochure, except that taken directly from copyrighted sources, is in the public domain and may be reproduced or copied without permission from SAMHSA/CSAT or the authors. Citation of the source is appreciated. However, this publication may not be reproduced or distributed for a fee without the specific, written authorization of the Office of Communications, SAMHSA, HHS.

**Electronic Access and Copies of Publication**
This brochure can be downloaded from the KAP Web site at http://www.kap.samhsa.gov. The Treatment Improvement Protocol series and its affiliated products may be downloaded from SAMHSA's Health Information Network (SHIN) Web site at http://www.samhsa.gov/shin.

**Originating Office**
Quality Improvement and Workforce Development Branch, Division of Services Improvement, Center for Substance Abuse Treatment, Substance Abuse and Mental Health Services Administration, 1 Choke Cherry Road, Rockville, MD 20857. HHS Publication No. (SMA) 10-4292Khmer. Adapted and translated from English version in 2010. Original English version produced in 2007.

A Life in the Community for Everyone

SAMHSA

Substance Abuse and Mental Health Services Administration

U.S. Department of Health and Human Services